ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅទីក្រុង អង់តាណាណារីវ៉ូ ប្រទេសម៉ាដាហ្គាស្ការ ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើទី ១៦ តាមការអញ្ជើញរបស់ឯកឧត្តម ហេរី រ៉ាចៅណារីម៉ាមព្យ៉ានីណា (Hery RAJAONARIMAMPIANINA) ប្រធានាធិបតីនៃសាធារណរដ្ឋម៉ាដាហ្គាស្ការ ។

គណៈប្រតិភូដែលបានចូលរួមនៅក្នុងកិច្ចប្រជុំកំពូលនេះ មានចំនួនជាង ៦៥០០ នាក់ ក្នុងនោះមានថ្នាក់ប្រមុខរដ្ឋ/ រដ្ឋាភិបាល ២០ ប្រទេស និងប្រតិភូតំណាងប្រមាណ ២៥០០ នាក់ មកពី ៨០ ប្រទេសសមាជិក (សមាជិកពេញសិទ្ធិ ៥៧ និងសង្កេតការណ៍ ២៣) នៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) និងតំណាងអង្គការអន្តរជាតិជាដៃគូ ដូចជាក្រុមប្រឹក្សាសន្តិសុខ និងដេប៉ាតឺម៉ង់ប្រតិបត្តិការថែរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប សហភាពអាហ្វ្រិក ព្រមទាំងធនាគារអាហ្វ្រិកសម្រាប់ការអភិវឌ្ឍន៍ ។

នៅក្នុងកិច្ចប្រជុំកំពូលលើកទី ១៦ នៃអង្គការហ្វ្រង់កូហ្វូនី ដែលដឹកនាំដោយប្រធានាធិបតីនៃសាធារណរដ្ឋម៉ាដាហ្គាស្ការនេះ ប្រមុខរដ្ឋ/រដ្ឋាភិបាលបានសម្រេចអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងអង់តាណាណារីវ៉ូ នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ សេចក្តីថ្លែងការណ៍នេះ រំឭកជាថ្មីនូវចំណង់ដែលមិនអាចញែកបានរវាងកំណើនដែលមានការបែងចែក និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងទទួលខុសត្រូវ ដើម្បីជានាស្ថិរភាពពិភពលោក និងនៅក្នុងបណ្តាប្រទេសហ្វ្រង់កូហ្វូន ។ សេចក្តីថ្លែងការណ៍បានសង្កត់ធ្ងន់លើការលើកកម្ពស់តម្លៃហ្វ្រង់កូហ្វូន ក្នុងការបំរើសាកលភាវូបនីយកម្មឱ្យកាន់តែមានភាពសុខដុមរមនា និងកំណត់ការអភិវឌ្ឍន៍ដោយចីរភាពនិងទទួលខុសត្រូវ រួមទាំងថាមពលសម្រាប់ទាំងអស់គ្នាជាគោលដៅអាទិភាព។

ប្រមុខរដ្ឋ/រដ្ឋាភិបាលដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ បានសម្តែងការសប្បាយរីករាយចំពោះភាពជឿនលឿននៃយុទ្ធសាស្ត្រសេដ្ឋកិច្ចសម្រាប់ហ្វ្រង់កូហ្វូនី ដោយផ្តោតលើការគាំទ្រសហគ្រិនភាព និងការបង្កើតការងារ។ បញ្ហាសន្តិសុខក៏ជាស្នូលនៃកិច្ចពិភាក្សាជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ដើម្បីជាគោលដៅរួមនៃការការពារប្រជាជនពីអំពើភេរវកម្ម រួមទាំងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម និងភាពជ្រុលនិយម ។

ជាមួយគ្នានេះដែរ កិច្ចប្រជុំកំពូលបានអនុម័តផងដែរនូវសេចក្តីសម្រេចចំនួន ១៣ ដែលផ្តោតទៅលើបញ្ហាផ្សេងៗគ្នា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃតម្លៃជាមូលដ្ឋានរបស់អង្គការហ្វ្រង់កូហ្វូនី រួមទាំងសកម្មភាពជាអាទិភាពសម្រាប់បណ្តាប្រទេសហ្វ្រង់កូហ្វូន និងស្ថិរភាពក្នុងពិភពលោក ដែលរួមមាន ៖ (១) សេចក្តីសំរេចស្តីពីស្ថានភាពវិបត្តិ ការចេញពីវិបត្តិ និងការពង្រឹងសន្តិភាព ក្នុងបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង (២) សេចក្តីសំរេច ស្តីពីការបង្កើតអង្គភាពអចិន្ត្រៃយ៍ក្នុងអង្គការ OIF ដើម្បីលើកតម្កើងភាពស្មើគ្នារវាងបុរស និងស្ត្រី សិទ្ធិ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (៣) សេចក្តីសំរេចស្តីពីការបង្ការលទ្ធិជ្រុលនិយម និងអំពើហឹង្សាជ្រុលដែលបង្កឱ្យមានអំពើភេរវកម្ម (៤) សេចក្តីសំរេចស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (៥) សេចក្តីសំរេចស្តីពីថាមពលស្អាត និងចីរភាពសំរាប់ប្រជាជននៅទ្វីបអាហ្វ្រិក (៦) សេចក្តីសំរេចស្តីពីការលើកតម្កើងពហុភាសា (៧) សេចក្តីសំរេចស្តីពីអាពាហ៍ពិពាហ៍កុមារ អាពាហ៍ពិពាហ៍មុនអាយុកាល និងអាពាហ៍ពិពាហ៍ដោយបង្ខំ (៨) សេចក្តីសំរេចស្តីពីវិមជ្ឈការ និងការអភិវឌ្ឍក្នុងតំបន់ (៩) សេចក្តីសំរេចស្តីពី "ធនធានទឹក សន្តិភាព និងសន្តិសុខ" (១០) សេចក្តីសំរេចស្តីពីការលើកតម្កើងវប្បធម៌សន្ទនា ដែលជាកត្តាអភិវឌ្ឍន៍ប្រកបដោយចីរភាព (១១) វិនិយោគក្នុងវិស័យសុខាភិបាល ដើម្បីទ្រទ្រង់កំណើនដែលមានការចែករំលែកក្នុងបណ្តាប្រទេសហ្វ្រង់កូហ្វូន (១២) សេចក្តីសំរេចស្តីពីសុវត្ថិភាពផ្លូវគោក និង (១៣)សេចក្តីសំរេចស្តីពីសេដ្ឋកិច្ចខៀវ ។

នៅក្នុងសន្និសីទកំពូលនេះ ប្រមុខរដ្ឋ/រដ្ឋាភិបាលបានអនុម័តបេក្ខភាពនៃរដ្ឋ/រដ្ឋាភិបាលចំនួន៤ ឲ្យក្លាយជាសមាជិកហ្វ្រង់កូហ្វូនី ៖ ប្រទេសនូវ៉ែល-កាឡេដូនី (Nouvelle-Calédonie) ជាសមាជិកមិនពេញសិទ្ធិ (membre associé) ប្រទេសអាហ្សង់ទីន (Argentine) ប្រទេសកូរ៉េខាងត្បូង (Corée du Sud) និង ខេត្តអុងតារីយ៉ូនៃប្រទេសកាណាដា(Canada-Ontario) ជាសមាជិកសង្កេតការណ៍។

កិច្ចប្រជុំកំពូលក៏បានសម្រេចឱ្យប្រទេសអាម៉េនី (Arménie) ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទកំពូលហ្វ្រង់កូហ្វូនីលើកទី ១៧ នៅឆ្នាំ ២០១៨ និងប្រទេសទុយនីស៊ី (Tunisie) ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទកំពូលហ្វ្រង់កូហ្វូនីលើកទី ១៨ នៅឆ្នាំ ២០២០ ដែលនឹងជាខួបលើកទី ៥០ ឆ្នាំ នៃអង្គការហ្វ្រង់កូហ្វូនី។

បន្ទាប់ពីចូលរួមក្នុងកិច្ចប្រជុំកំពូលលើកទី១៦នៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅប្រទេសបារាំង ពីថ្ងៃទី ២៨ ដល់ ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ តបតាមការអញ្ជើញរបស់ឯកឧត្តម ហ្សង់ ម៉ាក អេរ៉ូ (Jean-Marc AYRAULT) រដ្ឋមន្ត្រីការបរទេស និងអភិវឌ្ឍន៍អន្តរជាតិនៃសាធារណរដ្ឋបារាំង ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ច **ឯកឧត្តមទេសរដ្ឋមន្ត្រី** និង សមភាគីបារាំង សំដែងនូវសេចក្តីសប្បាយរីករាយអំពីកិច្ចសហប្រតិបត្តិការមិត្តភាពជាប្រវត្តិសាស្ត្ររវាងប្រទេសទាំងពីរ និងបានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យសម្រាប់នាពេលអនាគត ជាពិសេសលើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ អប់រំ វប្បធម៌ សន្តិសុខ ព្រមទាំងពិភាក្សាលើប្រធានបទដែលជាអត្ថប្រយោជន៍រួមនៃប្រទេសទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារសំខាន់នៃការចូលរួមចំណែករបស់ប្រទេសបារាំងក្នុងការធ្វើឲ្យមានសន្តិភាពឡើងវិញនៅកម្ពុជា ការកសាងប្រទេសកម្ពុជាឡើងវិញ ជាពិសេសការអភិវឌ្ឍន៍ធនធានមនុស្ស សេដ្ឋកិច្ចសង្គមកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩០ និងការលើកតម្កើងបេតិកភ័ណ្ឌវប្បធម៌កម្ពុជា ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងការសប្បាយរីករាយចំពោះការផ្លាស់ប្តូរសេដ្ឋកិច្ចរវាងប្រទេសទាំងពីរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងមានបំណងឱ្យការផ្លាស់ប្តូរសេដ្ឋកិច្ចនេះ ត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការវិនិយោគបារាំងនៅកម្ពុជា កាន់តែច្រើនឡើង ។ ឯកឧត្តម **ហ្សង់ ម៉ាក អេរ៉ូ** បានគូសបញ្ជាក់ថា ប្រទេសបារាំងរីករាយបន្តចូលរួមអមដំណើរការអភិវឌ្ឍ និងការរីកចម្រើននៃប្រទេសកម្ពុជា លើវិស័យជាអាទិភាព ដូចជាសេដ្ឋកិច្ច ទេសចរណ៍ បេតិកភណ្ឌ កសិកម្ម ក្នុងប្រតិបត្តិការថែរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ក្នុងវិស័យអភិវឌ្ឍន៍ដោយចីរភាព ជាពិសេសការផ្តល់សច្ចាប័ននាពេលថ្មីៗនេះរបស់កម្ពុជាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ។ ឯកឧត្តម **ហ្សង់ ម៉ាក អេរ៉ូ** បានយល់ស្របជាមួយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** លើទំនាក់ទំនងសេដ្ឋកិច្ចដ៏ល្អរវាងប្រទេសទាំងពីរ និងមានបំណងឱ្យទំនាក់ទំនងសេដ្ឋកិច្ចនេះពង្រឹងបន្ថែមទៀត ជាពិសេស តាមរយៈវត្តមានសហគ្រាសធុនតូច និងមធ្យម ដែលភាគច្រើនស្ថិតក្នុងវិស័យអភិវឌ្ឍដោយចីរភាព ក្នុងនយោបាយសង្គម និងបរិស្ថាន ដែលបន្ថែមលើក្រុមហ៊ុនធំៗដែលមានវត្តមានរួចហើយនៅកម្ពុជា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងឯកឧត្តម **ហ្សង់ ម៉ាក អេរ៉ូ** ក៏បានពិភាក្សាផងដែរអំពីការវិវត្តថ្មីៗនៃបច្ចុប្បន្នភាពតំបន់ និងពិភពលោក ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជួបទទួលទានអាហារថ្ងៃត្រង់ការងារជាមួយលោកជំទាវ **កាតេរីន កេរ៉េ** (Catherine QUÉRÉ) ប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា និងដោយមានការចូលរួមផងដែរពីឯកឧត្តម **ហ្ស៊ីងសង់ អេប្លេ** ប្រធានក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា និងឡាវ។ ក្នុងអំឡុងពេលជួបពិភាក្សាការងារ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីទំនាក់ទំនងដ៏ល្អនៃប្រទេសទាំងពីរលើវិស័យបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ជាពិសេស អ្នកច្បាប់កម្ពុជាដែលចេះភាសាបារាំង ការវិវត្តនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលការណ៍នីតិរដ្ឋ ។

តាមរយៈដំណើរទស្សនកិច្ចជាច្រើនលើកនៅកម្ពុជា ប្រធានក្រុមមិត្តភាពរដ្ឋសភា ព្រឹទ្ធសភាបារាំង-កម្ពុជា បានកត់សំគាល់ពីការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់កម្ពុជាលើវិស័យសេដ្ឋកិច្ច ទេសចរណ៍ និង បានគូសបញ្ជាក់ពីសារសំខាន់នូវការគោរពគោលការណ៍ប្រជាធិបតេយ្យ តាមរយៈការរៀបចំបោះឆ្នោតដោយសេរី និងយុត្តិធម៌ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងគណៈប្រតិភូបានអញ្ជើញទៅទស្សនាសាលាបារាំងចុងបូព៌ា (EFEO)។ ក្នុងពេលជំនួបជាមួយ លោក **អ៊ីវ ហ្គូឌីណូ** (Yves Goudineau) នាយកសាលាបារាំងចុងបូព៌ា **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអបអរសាទរចំពោះការងារគួរឲ្យកត់សម្គាល់របស់សាលាបារាំងចុងបូព៌ា ក្នុងការលើកកម្ពស់តម្លៃបេតិកភណ្ឌវប្បធម៌កម្ពុជាតាំងពីជាងមួយសតវត្សមកនេះ ។

ក្នុងពេលទស្សនាមូលនិធិ ផាល ដឺហ្គោល **ឯកឧត្តមទេសរដ្ឋមន្ត្រី** និង ឯកឧត្តម **ហ្សាក់ ហ្គូដហ្វ្រាំង** (Jacques Godfrain) ប្រធានមូលនិធិ ផាល ដឺហ្គោល បានរំឭកពីដំណើរជីវិតរបស់ ឧត្តមសេនីយ៍ **ផាល ដឺហ្គោល** អ្នកមានទស្សនវិស័យវែងឆ្ងាយ ដែលសុន្ទរកថាទីក្រុងភ្នំពេញជាប្រវត្តិសាស្ត្រកាលពីខែកញ្ញា ឆ្នាំ ១៩៦៦ ស្ថិតនៅជាបច្ចុប្បន្នភាព។

ភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៦